ទស្សនៈ អ្នកនិពន្ធ

វ៉ុល៣, លេខ១៦, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១

# តើនឹងមានអ្វីបន្ទាប់ពីទណ្ឌកម្មសព្វាវុធរបស់អាមេរិកមកលើកម្ពុជា

បណ្ឌិត អ៊ុន ឃាង *

ខ្ញុំធ្លាប់បានសរសេរនៅលើវេទិកាមតិនេះ ដោយបង្ហាញពីការព្រួយបារម្ភថា រដ្ឋាភិបាលអាមេរិកអាចនឹងបន្តប្រើការចោទប្រកាន់អំពីវត្តមានយោធាចិននៅកម្ពុជា ដើម្បីដាក់សម្ពាធលើកម្ពុជា និងព្រមានប្រទេសផ្សេងទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មិនឱ្យរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយចិន។ ទង្វើបែបនេះគឺជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់អាមេរិក ក្នុងការបិទខ្ទប់ចិន ដែលអំណាចនៃប្រទេសមួយនេះកំពុងកើនឡើង តាមរយៈគំរូអភិបាលកិច្ចថ្មី ឈរលើអំណាចសេដ្ឋកិច្ច និងយោធាដ៏រឹងមាំ។ ហើយដូច្នេះ ចិនជាប្រទេសមានសក្តានុពលក្នុងការកែប្រែប្រព័ន្ធអន្តរជាតិ ដែលប្រទេសអាមេរិកធ្លាប់បានគ្រប់គ្រង ចាប់តាំងពីការបញ្ចប់នៃសង្គ្រាមត្រជាក់។ ក្តីបារម្ភពីមុនរបស់ខ្ញុំបានក្លាយជាការពិតកាលពីសប្តាហ៍មុន នៅពេលដែលអាមេរិកបានសម្រេចចិត្តដាក់ទណ្ឌកម្មការនាំចេញនាំចូលសព្វាវុធមកកម្ពុជា ដែល រួមមាន "សម្ភារដែលអាចប្រើប្រាស់បានពីរយ៉ាង (បែបយោធា និងស៊ីវិល) ក៏ដូចជាសម្ភារយោធាដែលមិនសូវមានភាពរសើបមួយចំនួន"។

តាមពិត ទណ្ឌកម្មការនាំចេញនាំចូលសព្វាវុធមក កម្ពុជានេះគ្រាន់តែជានិមិត្តរូបតែប៉ុណ្ណោះ ដោយសារអាមេរិកមិនមែនជាអ្នកផ្គត់ផ្គង់គ្រឿងសព្វាវុធដល់កម្ពុជានោះទេ។ វាគ្រាន់តែជាការព្រមានមួយបន្ថែមទៀតលើកម្ពុជា ទាក់ទងនឹងទំនាក់ទំនងជិតស្និទ្ធរបស់កម្ពុជាជាមួយចិន។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនស្តីពីទណ្ឌកម្មការនាំចេញនាំចូលសព្វាវុធនេះ រដ្ឋាភិបាលអាមេរិកបានអះអាងថា "អាមេរិកនៅតែបន្តប្តេជ្ញាចិត្តយ៉ាងពេញលេញក្នុងការគោរពឯករាជ្យភាពរបស់កម្ពុជា និងអធិបតេយ្យភាពរបស់ប្រជាជនកម្ពុជា"។ ទង្វើរបស់រដ្ឋាភិបាលអាមេរិក រាប់ចាប់ពីការចោទប្រកាន់អំពីកិច្ចព្រមព្រៀងសម្ងាត់រវាងកម្ពុជា និងចិន ក្នុងការអនុញ្ញាតឱ្យចិនដាក់កងទ័ពរបស់ខ្លួននៅកម្ពុជា រហូតដល់ទណ្ឌកម្មការនាំចេញនាំចូលសព្វាវុធថ្មីៗនេះ គឺគ្មានអ្វីក្រៅពីការរំលោភលើឯករាជ្យភាព និងអធិបតេយ្យភាពរបស់កម្ពុជានោះទេ។ វាគឺជាឧទាហរណ៍ជាក់ស្តែងនៃនយោបាយពិតប្រាកដ ដែលផ្អែកលើគោលការណ៍ដែលថា "អ្នកខ្លាំងតែងតែត្រូវ"។ អាមេរិកប្រើអំណាចអនុត្តរភាពរបស់ខ្លួនដើម្បីដាក់សម្ពាធលើប្រទេសទន់ខ្សោយដើម្បីឱ្យគេគាំទ្រលើយុទ្ធសាស្ត្របិទខ្ទប់ចិនរបស់ខ្លួន។ វាជាសកម្មភាពដែលជ្រៀតជ្រែកដល់សិទ្ធិរបស់កម្ពុជា ក្នុងការធ្វើកិច្ចការបរទេសរបស់ខ្លួនយ៉ាងច្បាស់។ ក្នុងនាមជាប្រទេសអធិបតេយ្យកម្ពុជាមានសិទ្ធិស្របច្បាប់ពេញលេញ ក្រោមបទដ្ឋាន និងច្បាប់អន្តរជាតិ ដែលកម្ពុជាគួរតែអាចអភិវឌ្ឍទំនាក់ទំនង

* **បណ្ឌិត អ៊ុន ឃាង** គឺជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យ Northern Illinois សហរដ្ឋអាមេរិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

*© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

ជិតស្និទ្ធជាមួយចិន ដែលជាសមាជិកពេញសិទ្ធិ និងមានទំនួលខុសត្រូវមួយនៃសហគមន៍អន្តរជាតិ។

ផ្ទុយទៅនឹងការអះអាងរបស់អ្នកបង្កើតគោលនយោបាយ អ្នកវិភាគ និងរបាយការណ៍ព័ត៌មានជាច្រើន ភស្តុតាងនៃការស្រាវជ្រាវបានបញ្ជាក់យ៉ាងច្បាស់ថា ពាណិជ្ជកម្ម ការវិនិយោគ និងជំនួយអភិវឌ្ឍន៍របស់ចិនបានជំរុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា និងនៅប្រទេសតតិយលោកដទៃទៀត រួមទាំងប្រទេសនៅទ្វីបអាហ្វ្រិកផងដែរ។ ប្រទេសជាច្រើននៅទ្វីបអាហ្វ្រិកបានជួបប្រទះការធ្លាក់ដុនដាបផ្នែកសេដ្ឋកិច្ចជាច្រើនទសវត្សរ៍ចាប់តាំងពីការទទួលបានឯករាជ្យពីមហាអំណាចអឺរ៉ុប ទោះបីជាមហាអំណាចទាំងនេះបន្តការផ្សារភ្ជាប់ទំនាក់ទំនងជាមួយប្រទេសទាំងនេះក្នុងរូបភាពជាជំនួយ ពាណិជ្ជកម្ម និងការវិនិយោគក៏ដោយ។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ទំនាក់ទំនងរបស់ប្រទេសទាំងនេះជាមួយចិន បាននាំមកនូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។[1] កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រដែលជាលទ្ធផលចេញពីកំណើនសេដ្ឋកិច្ចនេះ គឺជាធាតុផ្សំដ៏សំខាន់នៃសន្តិភាព និងស្ថិរភាពសង្គម។ ដូចអ្វីដែលបានធ្វើដាក់កម្ពុជា អាមេរិក និងសម្ព័ន្ធមិត្តរបស់ខ្លួនកំពុងដាក់សម្ពាធលើប្រទេសនៅអាហ្វ្រិក ដើម្បីកាត់បន្ថយទំនាក់ទំនងរបស់ពួកគេជាមួយចិន ដោយលើកឡើងពីការអះអាងមិនពិតដែលថា ការភ្ជាប់ជាមួយចិនផ្តល់ប្រយោជន៍ឱ្យតែចិនប៉ុណ្ណោះ ដោយលំហូរធនធាន និងប្រាក់ចំណេញចេញពីទ្វីបអាហ្វ្រិកទៅកាន់ចិន។

សម្រាប់កម្ពុជា សម្ពាធពីអាមេរិកនឹងបន្តមានក្នុងទម្រង់ណាមួយមិនខាន ដោយសារការអូសបន្លាយនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងអាមេរិក និងចិន។ នៅពេលនេះ ទោះបីជាទណ្ឌកម្មការនាំចេញនាំចូលសព្វាវុធរបស់អាមេរិកលើកម្ពុជា ព្រមទាំងទណ្ឌកម្មផ្សេងទៀតកន្លងមក គឺគ្រាន់តែជានិមិត្តរូបក៏ដោយ តែវាក៏ភ្ជាប់មកជាមួយនឹងការព្រមានថានឹងមានការដាក់ទណ្ឌកម្មជាបន្តបន្ទាប់ទៀត។ អាមេរិកនៅតែមិនទាន់បានដាក់សម្ពាធធ្ងន់ធ្ងរមកលើកម្ពុជានៅឡើយ នោះគឺការដកហូតការអនុគ្រោះពាណិជ្ជកម្មដែលខ្លួនផ្តល់ឱ្យកម្ពុជាក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅ។ យើងគ្រាន់តែសង្ឃឹមថា អាមេរិកនឹងមិនជ្រើសយកជម្រើសនោះមកប្រើប្រាស់ឡើយ ពីព្រោះការធ្វើបែបនេះ គឺស្មើនឹងការរំលោភសិទ្ធិមនុស្សជាមូលដ្ឋាន ដែលជាសិទ្ធិក្នុងការរស់នៅបានសមរម្យរបស់ប្រជាជនកម្ពុជារាប់លាននាក់ ដែលជីវភាព និងការអប់រំរបស់ពួកគេ ពឹងផ្អែកលើប្រាក់ចំណូលរបស់កម្មកររោងចក្រកាត់ដេរ។

និយាយយ៉ាងដូច្នេះ ក៏មានន័យដែរថា កម្ពុជាគួរតែរៀបចំផែនការសម្រាប់ត្រៀមខ្លួនទប់ទល់នឹងសកម្មភាពរបស់រដ្ឋាភិបាលអាមេរិក ដែលមានរូបភាពកាន់តែធ្ងន់ធ្ងរទៅៗ ក្នុងបរិបទនៃការប្រកួតប្រជែងភូមិសាស្ត្រ ដែលមានសភាពកាន់តែតានតឹងឡើងរវាងចិន-អាមេរិក។ យើងអាចរៀនសូត្រពីប្រវត្តិសាស្ត្របានថា ក្នុងនាមការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ អាមេរិកជារឿយៗបានអះអាងថា "ខ្លួនត្រូវតែបង្ខំចិត្តធ្វើអំពើអាក្រក់ដើម្បីទទួលបានភាពប្រសើរឡើង"។ ទណ្ឌកម្មរបស់បស្ចិមប្រទេសមកលើកម្ពុជា ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដឹកនាំដោយអាមេរិក គឺជាសក្ខីភាពនៃការ "ដាក់ទណ្ឌកម្មអ្នកក្រ" ដើម្បីយកឈ្នះសង្គ្រាមមនោគមវិជ្ជារបស់ខ្លួន

[1] Deborah Brautigam, *The Dragon's Gift: the Real Story of China in Africa* (Oxford University Press, 2011), and Dambisa Moyo, *Dead Aid: Why aid Is Not Working and How There Is a Better Way for Africa* (Macmillan, 2009).

ជាមួយសហភាពសូវៀត។[2] បរិបទពិភពលោកក្នុងសតវត្សរ៍ទី២១ គឺខុសពីសតវត្សរ៍ទី២០។ ចិនគឺខុសគ្នាទាំងស្រុងពីអតីតសហភាពសូវៀត។ ពិភពលោកមានភាពស្មុគស្មាញ និងមានទំនាក់ទំនងគ្នាដោយសារការពឹងផ្អែកសេដ្ឋកិច្ចលើគ្នាទៅវិញទៅមកមានកម្រិតខ្ពស់។ ដូច្នេះ កម្ពុជាអាចទប់ទល់នឹងសម្ពាធរបស់អាមេរិកបាន ប្រសិនបើកម្ពុជារៀបចំខ្លួនដើម្បីទទួលបានអត្ថប្រយោជន៍នៃការពឹងផ្អែកគ្នាទៅវិញទៅមកជាសាកល រួមទាំងទំនាក់ទំនងជិតស្និទ្ធជាមួយចិន។ ការត្រៀមខ្លួននេះធ្វើឱ្យកម្ពុជាបន្តអនុវត្តឱ្យបានពេញលេញ នូវកំណែទម្រង់អភិបាលកិច្ច ការធ្វើពិពិធកម្មសេដ្ឋកិច្ច កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការបណ្តុះ បណ្តាលធនធានមនុស្ស និងការកៀរគរធនធាននានា។ មានតែតាមរយៈការពង្រឹងខ្លួនឯងពីខាងក្នុងទេ ទើបកម្ពុជាអាចទប់ទល់នឹងសម្ពាធពីខាងក្រៅបាន!

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
The Kampus Building, Unit 1D, Street 93, Sangkat Tonle Bassac, Khan Chamkarmon
info@cd-center.org | (+855) 10 950 456 www.cd-center.org
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

[2] Eva Mysliwiec, *Punishing the Poor: The International Isolation of Kampuchea* (Oxfam GB, 1988).